## What is Marine Cargo Insurance?

Campu Lonpac Marine Cargo Insurance covers the loss or damage to your goods during transportation from one place to another. The sum insured will be determined by the invoice value of the goods.

## Marine Cargo Insurance mainly covers three modes of transportation:

- Shipment by Vessel
- Sending by Air Freight
- Transit by Land Conveyance

## What does it cover?

Here is an example of risks covered and excluded based on **All Risks** cover

| CAUSES OF LOSS / DAMAGE TO THE GOODS | COVERED | EXCLUDED |
|---|---|---|
| Fire or explosion | ✓ | |
| Overturning or derailment of land conveyance | ✓ | |
| Vessel being stranded, grounded, sunk or capsized | ✓ | |
| Earthquake, volcanic eruption or lightning | ✓ | |
| Washing overboard | ✓ | |
| Damage by entry of sea, lake or river water into vessel craft, hold, conveyance, container, liftvan or place of storage | ✓ | |
| Total loss of any packages lost overboard or dropped whilst loading on to or unloading from vessel or craft | ✓ | |
| Piracy and theft, pilferage and non-delivery | ✓ | |
| Rough handling causing damage to the goods | ✓ | |
| Jettison | ✓ | |
| General Average Sacrifice | ✓ | |
| General Average & Salvage Charges | ✓ | |
| Contamination | ✓ | |
| Collision or contact of vessel/craft/land conveyance with external object other than water | ✓ | |
| Discharge of cargo at a port of distress | ✓ | |
| Ordinary leakage, loss in weight, wear and tear | | X |
| Scratching, rusting and denting, willful misconduct of the Assured | | X |
| Mechanical, electronic and electrical breakdown | | X |
| Insolvency of financial default of carrier | | X |
| Unseaworthiness of vessel | | X |
| Insufficiency or unsuitability of packing | | X |
| Delay and/inherent vice or loss of market | | X |

## We can cover the following voyages:

**Port to Port**
From port of origin to port of destination

**Door to Door**
From seller's premises to buyer's premise including inland transit

**Port to Door**
From port of origin to buyer's premise including inland transit

**Door to Port**
From seller's premises, including inland transit, to port of destination

## Who needs Marine Cargo Insurance?

Marine Cargo Insurance indemnifies the following parties against financial loss arising as a result of physical loss and/or damage during the transportation of goods:

- Importers
- Exporters
- Manufacturers
- Trading Companies
- Freight Forwarders

## Who should arrange the insurance?

The trade terms stated on the sales contract between the seller and the buyer will determine the voyage and by whom an import or export of goods should be insured. It is necessary to understand when the risk and ownership of the goods passes from the seller to the buyer under the different types of contract of sale by reference to the International Common Trade Terms (INCOTERMS).

## What are the most common types of sales contract used in trading?

**F.O.B / C.F.R**
F.O.B means Goods sold on Free On Board and CFR means Goods sold on Cost and Freight. Under this trade term the buyer is responsible to purchase the insurance.

**C.I.F**
This means Goods sold on Cost, Insurance and Freight. Here the seller undertakes to arrange and pay for all costs of delivering the goods including insurance up to final destination because the buyer has paid for these in the invoice price. The policy is assigned to the buyer and he can claim as though he had arranged for the insurance himself.

## What are the documents required to purchase Marine Cargo Insurance?

- Invoice of the goods
- Bill of lading
- Packing list
- Letter of credit (if applicable)

Note: For specific terms and conditions, please refer to our policy wording.

BR-M-1211/v2.0


ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី
CAMPU LONPAC INSURANCE PLC.

7th Floor, Campu Bank Building
No. 23, Street 114, Sangkat Phsar Thmey II, Khan Daun Penh
Phnom Penh, Royal Kingdom of Cambodia.
P.O Box 1556

Tel: +855 23 966 966 | Fax: + 855 23 986 273
24 Hours Claims Hotline: 016 810 999/ 017 799 903
E-mail: enquiries@campulonpac.com.kh
Website: www.campulonpac.com.kh


ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក

CAMPU LONPAC INSURANCE

# កិច្ចសន្យាធានារ៉ាប់រង លើការដឹកជញ្ជូនទំនិញ

# Marine Cargo Insurance



## តើអ្វីទៅជាកិច្ចសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ?

កិច្ចសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញរបស់ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ធានាលើការបាត់បង់ ឬខូចខាតទំនិញរបស់លោកអ្នកក្នុងកំឡុងពេលទំនិញត្រូវបានផ្ទេរពីកន្លែងមួយទៅកន្លែងមួយ ។ តំលៃធានារ៉ាប់រងសរុបនឹងត្រូវកំណត់តាមរយៈវិក្កយបត្រនៃមុខទំនិញ ។

## តើកិច្ចសន្យាធានារ៉ាប់រងនេះ គ្របដណ្តប់លើអ្វីខ្លះ?

នេះជាឧទាហរណ៍នៃហានិភ័យដែលត្រូវធានារ៉ាប់រង និងករណីលើកលែង៖

| មូលហេតុនៃការបាត់បង់ ឬការខូចខាតចំពោះទំនិញ | ធានារ៉ាប់រង | ករណីលើកលែង |
|---|---|---|
| អគ្គិភ័យ ឬ ការផ្ទុះនានា | ✓ | |
| ការក្រឡាប់ ឬការធ្លាក់ផ្លូវនៃមធ្យោបាយដឹកជញ្ជូនផ្លូវដែក | ✓ | |
| ការកល់ ជាប់គៀង លិច ឬផ្អៀងនាវា | ✓ | |
| ការរញ្ជួយផែនដី បន្ទុះភ្នំភ្លើង ឬរន្ទះ | ✓ | |
| ការលិចនាវា | ✓ | |
| ការលិចទឹកសមុទ្រ ទឹកទន្លេ ទឹកបឹង ចូលក្នុងនាវា កុងទ័រន័រ ឬកន្លែង ស្តុកឥវ៉ាន់ជាដើម | ✓ | |
| ការខូចខាតទាំងស្រុងនូវកញ្ចប់ទំនិញ ដោយសារការលិច ឬធ្លាក់ក្នុងទឹកខណៈពេលដែលលើកឡើង ឬដាក់ចុះពីនាវា | ✓ | |
| ចោរសមុទ្រ និងអំពើចោរកម្ម ចោរប្លន់ដែលបណ្តាលអោយការដឹកជញ្ជូនមិនបានដល់គោលដៅ | ✓ | |
| ការលើក ឬដាក់ដែលធ្វើខូចខាតដល់ទំនិញ | ✓ | |
| ការទម្លាក់ផ្នែកខ្លះនៃទំនិញ ឬនាវាចូលក្នុងទឹកសមុទ្រដើម្បីរក្សាសុវត្ថិភាព និងអាចអោយនាវាអាចបើកបរដល់គោលដៅ | ✓ | |
| General Average Sacrifice | ✓ | |
| General Average & Salvage Charge | ✓ | |
| ការខូចខាតទំនិញដែលបណ្តាលមកពីការរីករាលដាលនៃសារធាតុគីមីផ្សេងៗ ដែលបានផ្ទុកក្នុងនាវាជាមួយគ្នា | ✓ | |
| ការបុកប៉ះទង្គិចនៃនាវា យន្តហោះ និងមធ្យោបាយដឹកជញ្ជូនផ្លូវគោកនានា | ✓ | |
| ការផ្ទេរទំនិញនៅកំពង់ផែ | ✓ | |
| ការលិច ឬជ្រាប ការបាត់បង់ទំងន់ សំណឹករិចរិល | | X |
| ការឆ្កូត ច្រេះ ឬកំពៀត និងការរៀបចំទុកដាក់ទំនិញមិនត្រឹមត្រូវដោយចេតនា | | X |
| ការខូចខាតមេកានិច បច្ចេកទេស ឬខូចខាតផ្នែកអគ្គិសនី | | X |
| ការខកខានមិនបានបង់ថ្លៃដឹកជញ្ជូន | | X |
| នាវាដែលមានលក្ខណៈបច្ចេកទេសមិនគ្រប់គ្រាន់ ក្នុងការដឹកជញ្ជូនទំនិញ | | X |
| ការវេចខ្ចប់មិនត្រឹមត្រូវ | | X |
| ការពន្យាពេលដែលនាំអោយបាត់បង់ទីផ្សារ | | X |

## កិច្ចសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ ធានារ៉ាប់រងលើការផ្ទេរទំនិញតាមរយៈមធ្យោបាយ ៣បែបគឺ

- ការដឹកជញ្ជូនទំនិញតាមនាវា
- ការបញ្ជូនទំនិញតាមយន្តហោះ
- ការបញ្ជូនទំនិញតាមមធ្យោបាយដឹកជញ្ជូនផ្លូវគោក

## យើងខ្ញុំអាចធ្វើការធានារ៉ាប់រងលើការផ្ទេរទំនិញតាមមធ្យោបាយដឹកជញ្ជូនផ្លូវទឹកដូចខាងក្រោម:

**ពីកំពង់ផែមួយទៅកំពង់ផែមួយ៖**
ពីកំពង់ផែចេញដំណើរទៅកំពង់ផែគោលដៅ

**ពីអ្នកលក់ទៅអ្នកទិញ៖**
ពីកន្លែងអ្នកលក់ទៅកន្លែងអ្នកទិញដោយរួមបញ្ចូលទាំងការផ្ទេរទំនិញលើគោក

**ពីកំពង់ផែចេញដំណើរទៅកន្លែងអ្នកទិញ៖**
ពីកំពង់ផែចេញដំណើរទៅទីកន្លែងអ្នកទិញដោយរួមបញ្ចូលទាំងការផ្ទេរទំនិញលើគោក ។

**ពីកន្លែងអ្នកលក់ទៅកំពង់ផែគោលដៅ៖**
ពីទីកន្លែងអ្នកលក់ទៅកំពង់ផែគោលដៅដោយរួមបញ្ចូលទាំងការផ្ទេរទំនិញលើគោក ។

## តើអ្នកណាខ្លះត្រូវការកិច្ចសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ?

កិច្ចសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញនឹងធ្វើសំណងចំពោះការខាតបង់ផ្នែកហិរញ្ញវត្ថុដែលអាចកើតមានឡើងដោយសារការបាត់បង់ ឬខូចខាតទំនិញក្នុងកំឡុងពេលដឹកជញ្ជូនចំពោះភាគីដូចខាងក្រោម៖

- អ្នកនាំទំនិញចូល
- អ្នកនាំទំនិញចេញ
- អ្នកផលិត
- ក្រុមហ៊ុនពាណិជ្ជកម្ម
- ក្រុមហ៊ុនដឹកជញ្ជូនទំនិញ

## អ្នកណាខ្លះគួរតែរៀបចំកិច្ចសន្យាធានារ៉ាប់រងនេះ?

លក្ខខណ្ឌអាជីវកម្មបានបញ្ជាក់នៅក្នុងកិច្ចសន្យាលក់ទំនិញរវាងអ្នកលក់ និងអ្នកទិញដែលកំនត់អំពីមធ្យោបាយដឹកជញ្ជូនទំនិញ និងកំណត់ថាតើអ្នកនាំទំនិញចូល ឬអ្នកនាំទំនិញចេញដែលគួរតែរៀបចំនូវកិច្ចសន្យាធានារ៉ាប់រង ។ វាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់អំពីហានិភ័យ និងភាពជាកម្មសិទ្ធិនៅពេលទំនិញត្រូវបានផ្ទេរពីអ្នកលក់ទៅអ្នកទិញក្រោមកិច្ចសន្យាលក់ទំនិញផ្សេងៗគ្នាដោយផ្អែកលើលក្ខខណ្ឌអាជីវកម្មច្បាប់អន្តរជាតិ ។

## តើកិច្ចសន្យាលក់ទំនិញណាខ្លះ ដែលគេនិយមប្រើប្រាស់ជាងគេនៅក្នុងវិស័យពាណិជ្ជកម្ម?

**F.O.B / C.F.R**

F.O.B (Free On Board) មានន័យថា ទំនិញដែលលក់ដោយមិនគិតថ្លៃដឹកជញ្ជូន ។ C.F.R (Cost and Freight) មានន័យថា ទំនិញដែលលក់គិតលើតំលៃដើម និងថ្លៃដឹកជញ្ជូន ។ ក្នុងលក្ខខណ្ឌទាំងនេះអ្នកទិញត្រូវទទួលខុសត្រូវក្នុងការបង់ថ្លៃធានារ៉ាប់រង ។

**C.I.F**

C.I.F (Cost, Insurance and Freight) មានន័យថា ទំនិញដែលលក់អាស្រ័យលើថ្លៃដើម ថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូន ។ ករណីនេះអ្នកលក់ទទួលខុសត្រូវក្នុងការរៀបចំ និងចេញថ្លៃដឹកជញ្ជូនទំនិញរួមទាំងការបង់បុព្វលាភធានារ៉ាប់រងរហូតដល់ទីតាំងរបស់អ្នកទិញពីព្រោះអ្នកទិញបានចេញថ្លៃទាំងនោះនៅក្នុងវិក្កយបត្ររួចរាល់ហើយ ។ កិច្ចសន្យាធានារ៉ាប់រងនេះ និងផ្តល់សិទ្ធអោយអ្នកទិញ ហើយគាត់អាចធ្វើបណ្តឹងទាមទារសំណងលើការខូចខាតទំនិញពីក្រុមហ៊ុនធានារ៉ាប់រងដោយខ្លួនឯងផ្ទាល់ ។

## តើកិច្ចការសន្យាធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញត្រូវការឯកសារអ្វីខ្លះ?

- វិក្កយបត្រមុខទំនិញ
- តារាងទំនិញដែលបានដឹកជញ្ជូន
- បញ្ជីរាល់ការវេចខ្ចប់
- លិខិតសេវាឥណទាន (បើមាន)៖ LC

កំណត់សំគាល់៖ រាល់ ខ ចែង និងលក្ខខណ្ឌជាក់លាក់ទាំងអស់ត្រូវយោងទៅលើអត្ថន័យដែលមាននៅក្នុងកិច្ចសន្យាធានារ៉ាប់រងរបស់យើងខ្ញុំ ។


ក្រុមហ៊ុនធានារ៉ាប់រង កម្ពុឡុនប៉ាក ភីអិលស៊ី
CAMPU LONPAC INSURANCE PLC.



ជាន់ទី៧ នៃអគារកម្ពុប៊ែង
ផ្ទះលេខ ២៣ ផ្លូវលេខ ១១៤ សង្កាត់ផ្សារថ្មី ២ ខ័ណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ប្រអប់សំបុត្រ ១៥៥៦

ទូរស័ព្ទ៖ +៨៥៥ ២៣ ៩៦៦ ៩៦៦ | ទូរសារ៖ +៨៥៥ ២៣ ៩៨៦ ២៧៣
លេខទូរស័ព្ទប្រចាំការ២៤ម៉ោង៖ ០១៦ ៨១០ ៩៩៩/ ០១៧ ៧៩៩ ៩០៣
អ៊ីមែល៖ enquiries@campulonpac.com.kh
គេហទំព័រ៖ www.campulonpac.com.kh